UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

**អង្គការសហប្រជាជាតិ**
**ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា**

United Nations
**Human Rights**

# ការិយាល័យ OHCHR
# សូមអំពាវនាវឲ្យបញ្ចប់ការយាយីចំពោះអ្នកការពារសិទ្ធិមនុស្សនៅខេត្តរតនៈគិរី

ផ្ញើនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩។ លោកប៉ែន ប៊ុណ្ណា មន្ត្រីសម្របសម្រួលសមាគមអាដហុក និង លោករដ្ឋា វិសាល អ្នកយកព័ត៌មានវិទ្យុអាស៊ីសេរី ត្រូវបានតុលាការខេត្តរតនៈគិរីកោះហៅឲ្យចូលខ្លួនជាបន្តបន្ទាប់នៅថ្ងៃទី១៥ និង១៤ ខែកញ្ញា ដែលតាមសេចក្តីរាយការណ៍ថា ដើម្បីសាកសួរអំពីការចោទប្រកាន់ពីបទសមគំនិត ក្នុងការញុះញង់ឲ្យប្រព្រឹត្តបទល្មើសមិនជាក់លាក់ និងពីបទញុះញង់អ្នកភូមិឲ្យប្រព្រឹត្តអំពើហឹង្សា និងកាន់កាប់ដីធ្លីដោយខុសច្បាប់។ ការកោះហៅនេះ ទាក់ទងនឹងបណ្តឹងដែលប្តឹងចូលតុលាការកាលពីខែវិច្ឆិកា ឆ្នាំ២០០៨ ប្រឆាំងនឹងបុរសពីរនាក់ ដែលបានផ្តល់ប្រឹក្សាយោបល់ដល់អ្នកភូមិឲ្យការពារដីធ្លីរបស់ពួកគេជាមួយក្រុមហ៊ុនឯកជនមួយ។ ចាប់តាំងពីពេលនោះមក តុលាការពុំបានចាត់ការលើបណ្តឹងប្រឆាំងនឹងពួកគេឡើយ។

អស់រយៈពេលជាច្រើនឆ្នាំមកហើយ បុរសទាំងពីរនាក់នោះ ត្រូវបានយាយីនិងបំភិតបំភ័យពីអាជ្ញាធរខេត្ត និងតុលាការទាក់ទងនឹងការតស៊ូដ៏ស្វិតស្វាញរបស់ពួកគេ ក្នុងការការពារសិទ្ធិទាំងឡាយរបស់សហគមន៍ដែលត្រូវបានគេរឹបអូសយកដីធ្លី និងជីវភាពរស់នៅរបស់ពួកគេនៅខេត្តភាគឦសាន ។ កាលពីដើមខែសីហា លោកថៅ សារ៉ន ចៅក្រមតុលាការខេត្តរតនៈគិរី បានស្នើសុំឲ្យលោកប៉ែន ប៊ុណ្ណា ចេញពីខេត្តរតនៈគិរី បើមិនដូច្នោះទេ ត្រូវប្រឈមមុខនឹងការចោទប្រកាន់ក្នុងរឿងព្រហ្មទណ្ឌពីបទ "ញុះញង់" ។

ការចោទប្រកាន់ពីបទ "ញុះញង់" ត្រូវបានប្រើប្រាស់ខ្លាំងឡើងៗក្នុងប៉ុន្មានឆ្នាំថ្មីៗនេះដោយអាជ្ញាធរខេត្ត និងអាជ្ញាធរកណ្តាល ដើម្បីបំភិតបំភ័យអ្នកការពារសិទ្ធិមនុស្ស ដែលធ្វើការពាក់ព័ន្ធនឹងការផ្តល់ប្រឹក្សាយោបល់ និងជួយសហគមន៍មូលដ្ឋាន ដែលពាក់ព័ន្ធនឹងវិវាទដីធ្លី ក្នុងការអនុវត្តន៍ និងការពារសិទ្ធិរបស់ពួកគេដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ។

សមាគមអាដហុក បានសម្រេចធ្វើការផ្លាស់ប្តូរលោកប៉ែន ប៊ុណ្ណា ដើម្បីចៀសវាងពីចំណាត់ការតាមផ្លូវច្បាប់ទៅលើរូបលោក ប៉ុន្តែសមាគមបានបដិសេធពុំធ្វើការសុំទោសជាផ្លូវការបន្ថែមទៀតតាមសំណើរបស់លោកចៅក្រមឡើយ។

តាំងពីពេលនោះមកការចោទប្រកាន់ពីអំពើពុករលួយ និងការប្រព្រឹត្តខុសវិជ្ជាជីវៈប្រព្រឹត្តដោយចៅក្រមដដែលនេះ បានលេចជារូបរាងឡើង ហើយបច្ចុប្បន្ននេះក៏មានបណ្តឹងមួយ ត្រូវបានធ្វើឡើងប្រឆាំងនឹងលោកចៅក្រមទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ បណ្តឹងនេះ ក៏ត្រូវបានរាយការណ៍ តាមវិទ្យុអាស៊ីសេរីដែរ។

No. 10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: +(855) 23 212 579 or 213 587
E-mail: cambodia@ohchr.org Website: http://cambodia.ohchr.org

ការិយាល័យព្រួយបារម្ភថា ការចេញដីកាកោះនៅពេលនេះពាក់ព័ន្ធនឹងបណ្តឹងកាលពីខែវិច្ឆិកាឆ្នាំ២០០៨ ទំនងជាត្រូវបានប្រើប្រាស់ជាលេសមួយដើម្បីយាយីបន្ថែមទៀតដល់អ្នកទាំងពីរ ហើយតាមរយៈអ្នកទាំងពីរនេះ ក៏យាយីដល់អ្នកការពារសិទ្ធិមនុស្សដទៃទៀត និងសហគមន៍មូលដ្ឋានការពារសិទ្ធិរបស់ពួកខ្លួនចំពោះដីធ្លីរបស់ខ្លួន នៅក្នុងខេត្ត។ ការិយាល័យ ក៏ព្រួយបារម្ភថា នេះអាចជាការប៉ុនប៉ងមួយទៀតប្រើប្រាស់បណ្តឹងតាមផ្លូវតុលាការ ដើម្បីដាក់កំហិតលើសេរីភាពជាមូលដ្ឋាននៃការប្រមូលផ្តុំនិងការបញ្ចេញមតិពីបញ្ហាដែលពាក់ព័ន្ធនឹងផលប្រយោជន៍សាធារណៈក្នុងបរិបទនៃវិវាទដីធ្លីជាច្រើនដែលមិនទាន់ដោះស្រាយរួចនៅឡើយនៅក្នុងខេត្ត។

គិតត្រឹមខែមិថុនាឆ្នាំ២០០៩មានប្រជាពលរដ្ឋជាង៥០នាក់រួចមកហើយដែលត្រូវបានរាយការណ៍មកថាត្រូវបានឃុំខ្លួនពាក់ព័ន្ធនឹងវិវាទដីធ្លីរីឯចំនួនចោទប្រកាន់ពីបទព្រហ្មទណ្ឌលើបុគ្គលទាំងនេះក្នុងរឿងនេះនិងចំនួននៃការចាប់ខ្លួនកាន់តែកើនឡើងៗគួរឲ្យកត់សំគាល់នោះគឺដោយសារតែការចោទប្រកាន់ជាច្រើនមិនត្រូវបានចាត់ការឲ្យបានត្រឹមត្រូវទាន់នីតិវិធី ហើយអ្នកទាំងនោះមិនត្រូវបានដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន។

ការិយាល័យសូមរំលឹកឡើងវិញពីការអំពាវនាវរបស់ខ្លួនកាលពីលើកមុនដល់អាជ្ញាធរខេត្តឲ្យបញ្ឈប់នូវការយាយីនិងការបំភិតបំភ័យដែលនៅតែបន្តមានដល់អ្នកការពារសិទ្ធិមនុស្សនៅក្នុងខេត្ត ហើយចូលមកសន្ទនាដោយពិតប្រាកដជាមួយសហគមន៍ដែលពាក់ព័ន្ធនឹងដីធ្លីជាការប្រសើរជាង ដើម្បីដោះស្រាយវិវាទទាំងនោះតាមលក្ខណៈផ្លូវច្បាប់និងយុត្តិធម៌ដូចដែលមានចែងក្នុងច្បាប់។

ការិយាល័យសូមរំលឹកពីសេចក្តីប្រកាសឆ្នាំ១៩៩៩ ស្តីពីសិទ្ធិនិងការទទួលខុសត្រូវរបស់បុគ្គលក្រុមអង្គការសង្គមដើម្បីលើកកំពស់និងការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល (សេចក្តីប្រកាសអ្នកការពារសិទ្ធិមនុស្ស) ដែលនៅក្នុងសេចក្តីប្រកាសនោះសុំឲ្យរដ្ឋនានាចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីធានាឲ្យមានការការពារ ដោយអាជ្ញាធរមានសមត្ថកិច្ច ដល់បុគ្គលគ្រប់រូបទោះជាឯកត្តជនក្តី ជាក្រុមឬសមាគមជាមួយអ្នកដទៃក្តី ពីអំពើហឹង្សាការគំរាមកំហែងអំពើសងសឹកការរើសអើងដោយមិនអនុគ្រោះតាមព្រឹត្តហេតុឬតាមផ្លូវច្បាប់ ការកៀបសង្កត់ណាមួយឬសកម្មភាពតាមអំពើចិត្តផ្សេងទៀត ដោយសារតែការប្រើប្រាស់សិទ្ធិស្របច្បាប់របស់ខ្លួន ។